ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១០ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការប្តូរឈ្មោះស្រុកក្រចេះ ទៅជាស្រុកចិត្របុរី
និងការបង្កើតក្រុងក្រចេះ នៃខេត្តក្រចេះ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

សម្រេច

មាត្រា ១.-

ត្រូវបានប្តូរឈ្មោះស្រុកក្រចេះ ទៅជា ស្រុកចិត្របុរី នៃខេត្តក្រចេះ ។

មាត្រា ២.-

ត្រូវបានបង្កើត ក្រុងក្រចេះ នៃខេត្តក្រចេះ ដោយកាត់យកឃុំចំនួនប្រាំ គឺ ឃុំអូរឬស្សី ឃុំក្រចេះ

www.pheakdeylaw.com

ឃុំកោះទ្រង់ ឃុំក្រគរ និង ឃុំរកាកណ្តាល ពីស្រុកចិត្របុរី នៃខេត្តក្រចេះ ។

ព្រំប្រទល់រដ្ឋបាលនៃ ក្រុងក្រចេះ ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ។

មាត្រា ៣.-

ត្រូវបានប្តូរឃុំ ចំនួនប្រាំនៃ ក្រុងក្រចេះ ឱ្យទៅជាសង្កាត់ដូចមានខាងក្រោម :

១- ឃុំ អូរឫស្សី	ទៅជា	សង្កាត់អូរឫស្សី
២- ឃុំ ក្រចេះ	ទៅជា	សង្កាត់ក្រចេះ
៣- ឃុំ កោះទ្រង់	ទៅជា	សង្កាត់កោះទ្រង់
៤- ឃុំ ក្រគរ	ទៅជា	សង្កាត់ក្រគរ
៥-ឃុំ រកាកណ្តាល	ទៅជា	សង្កាត់រកាកណ្តាល

មាត្រា ៤.-

ត្រូវផ្ទេរទីតាំងសាលាស្រុកចិត្របុរី ដែលស្ថិតនៅសង្កាត់អូរឫស្សី ទៅជាសាលា ក្រុងក្រចេះ។

មាត្រា ៥.-

ទីតាំងសាលាស្រុកចិត្របុរី ត្រូវស្ថិតនៅក្នុងឃុំដារ ស្រុកចិត្របុរី ខេត្តក្រចេះ។

មាត្រា ៦.-

ការរៀបចំរចនាសម្ព័ន្ធ និង ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល ក្រុងក្រចេះ ត្រូវអនុលោមទៅតាមច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

មាត្រា ៧.-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៨.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាលខេត្តក្រចេះ អភិបាលក្រុងក្រចេះ អភិបាលស្រុកចិត្របុរី និង ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មករា ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

(ដើម្បីជូនជ្រាប)

- ដូចមាត្រា ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

www.pheakdeylaw.com



លេខ....០០៦ ៗ........
បានឃើញ និង ឯកភាព
ភ្នំពេញ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ២០០៩
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
ស ខេង

បានឃើញ និង ឯកភាព	បានឃើញ និង ឯកភាព	បានឃើញ និង ឯកភាព
ក្រចេះ ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០០៨	ក្រចេះ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០០៨	ក្រចេះ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០០៨
អភិបាលខេត្ត	ប្រធានមន្ទីរ រៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត	អភិបាលស្រុកក្រចេះ
ខាំ_ភឿន	ចាន់_សុផាត	ហ៊ៀ_ស៊ុំអៀម